# ឱវាទព្រះពុទ្ធចំពោះស្ត្រីដែលត្រូវរៀបអាពាហ៍ពិពាហ៍

(រៀបរៀងដោយភិក្ខុ **សឿន ធុទ្ធី** (M.A,Bdh,ITBMU)

ការរៀបអាពាហ៍ពិពាហ៍ ក្នុងសង្គមមនុស្ស ត្រូវបានធ្វើឡើងគ្រប់សម័យកាល ក្នុងប្រទេសនានា នៅលើសកលលោកយើងនេះ។

សម័យពុទ្ធកាល ក៏មានការរៀបអាវាហវិវាហមង្គលដែរ។យោងតាមឧគ្គហសូត្រ ក្នុងគម្ពីរអង្គុតរនិកាយជាភាសាបាលី, ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រទានឱវាទជាករណីយកិច្ច ដល់ស្ត្រីដែលនឹងត្រូវរៀបការជាមួយគូស្វាមី និងភារកិច្ចដែលមាន ក្នុងវង្ស់គ្រួសារ។

តទៅនេះ សូមធ្វើការរៀបរាប់ នូវពុទ្ធោវាទ៥យ៉ាងដោយសង្ខេប ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់សម្តែងទុក ក្នុងឧគ្គហសូត្រ ទាក់ទងនឹងករណីយកិច្ច ដែលស្ត្រីត្រូវធ្វើពេលមានគ្រួសារ។

កាលព្រះសម្មាសម្ពុទ្ធបានកំពុងគង់នៅក្នុងជាតិយវ័ន ជិតដែនភទ្ទិយ,គ្រានោះមាណពម្នាក់ឈ្មោះ ឧគ្គហៈ ជាចៅប្រុសរបស់មេណ្ឌកសេដ្ឋី បានចូលទៅគាល់ព្រះពុទ្ធ ហើយបាននិមន្តព្រះអង្គឱ្យទទួលភត្តនៅថ្ងៃស្អែក។បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់បានសោយចង្ហាន់ហើយ,ឧគ្គហមាណពបានអារាធនាព្រះអង្គ ឱ្យប្រទានឱវាទមួយចំនួន ចំពោះស្ត្រីដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ក្នុងពេលឆាប់ខាងមុខ។

ពេលនោះព្រះពុទ្ធទ្រង់បានសម្តែងប្រារព្ធចំពោះស្ត្រីដែលនឹងត្រូវធ្វើជាភរិយាគេនោះថា«អ្នកគប្បីបំពេញនូវករណីយកិច្ចទាំង៥យ៉ាង»គឺ៖

១. (ក)ត្រូវក្រោកពីព្រលឹមមុនស្វាមី

(ខ)ត្រូវចូលដំណេកក្រោយស្វាមី

(គ)ត្រូវរៀបចំគំរោងជាស្រេច សម្រាប់ការងារ

(ឃ)ត្រូវធ្វើការងារ ដោយល្អនិងរីករាយ និង

(ង) ត្រូវនិយាយពាក្យផ្អែមល្ហែម ដាក់ស្វាមី។

២. មានម្ដាយ ឪពុក សមណៈ និងព្រាហ្មណ៍ របស់ស្វាមីអ្នក។ដូច្នេះ អ្នកត្រូវថ្វាយបង្គំ គោរព វន្ទា ចំពោះអ្នកទាំងនោះ។

៣. មានកម្មករ ,អ្នកធ្វើការងារ របស់ស្វាមីអ្នក។ដូច្នេះ អ្នកត្រូវពិនិត្យ និងផ្ដល់ឱ្យពួកគេ នូវវត្ថុចាំបាច់នានា។

៤.មានឈ្នួលបម្រើ របស់ស្វាមីអ្នក។ដូច្នេះ អ្នកគប្បីដឹង នូវអ្វីដែលត្រូវបានធ្វើ និងអ្វីដែលមិនទាន់ត្រូវបានធ្វើ និងគប្បីផ្ដល់ម្ហូបអាហារ ដល់អ្នកដែលមានជម្ងឺ។

៥.ស្វាមី របស់អ្នកនឹងបាននាំមកនូវវត្ថុផ្សេងៗ ដូចជាទ្រព្យសម្បត្តិ ស្រូវ អង្ករ និងមាសប្រាក់ ជាដើម។ ដូច្នេះ អ្នកត្រូវរក្សាទុករបស់ទាំងនោះ ឱ្យបានល្អ និងមានសុវត្ថិភាព ហើយមិនត្រូវខ្ជះខ្ជាយរបស់ទាំងនោះឡើយ។

ប្រសិនបើអ្នកបានបំពេញករណីយកិច្ចទាំង៥នេះ ហើយ,អ្នកនឹងបានកើត ក្នុងឋានសួគ៌បន្ទាប់ពីមរណភាពទៅ។

ទាំងនេះជាឱវាទ របស់ព្រះពុទ្ធចំពោះស្ត្រី ដែលនឹងធ្វើជាភរិយាគេ។ បើស្ត្រីជាភរិយាទាំងឡាយ បានយល់ដឹងនូវពុទ្ធោវាទ៥យ៉ាងនេះហើយ យកទៅប្រតិបត្តិតាម គង់បានចម្រុងចម្រើន ត្រជាក់ត្រជុំ ក្នុងសង្គមគ្រួសារជាក់ជាមិនខាន៕

ចប់ដោយសង្ខេប